

# មហាអនុតំបន់ទន្លេមេគង្គ
# កម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ច

ADB

ក្នុងឆ្នាំ១៩៩២ ដោយមានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង តាមរយៈការពង្រឹងបន្ថែមទៅលើប្រវត្តិសាស្ត្រ និង វប្បធម៌របស់ពួកគេដែលមានលក្ខណៈស្រដៀងគ្នា ប្រទេសទាំង៦នៃមហាអនុតំបន់ទន្លេមេគង្គ (GMS) បានធ្វើការផ្សព្វផ្សាយកម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចនៃមហាអនុតំបន់ទន្លេមេគង្គ ដើម្បីលើកកម្ពស់ទំនាក់ទំនងសេដ្ឋកិច្ចរបស់ពួកគេ។

មហាអនុតំបន់ទន្លេមេគង្គ រួមមានប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន (PRC ជាពិសេសគឺខេត្តយូនណាន និងតំបន់ស្វយ័ត គ័ងស៊ី ហ្វ័ង) សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (Lao PDR) មីយ៉ាន់ម៉ា ថៃ និងវៀតណាម។ មហាអនុតំបន់ទន្លេមេគង្គ គឺជាតំបន់សេដ្ឋកិច្ចមួយបែបធម្មជាតិដែលត្រូវបានភ្ជាប់ទំនាក់ទំនងគ្នាដោយទន្លេមេគង្គ ដោយមានផ្ទៃដីចំនួន២,៦លានគីឡូម៉ែត្រការ៉េ និងប្រជាជនសរុបចំនួន ៣៣៣,៨លាននាក់។

ដោយមានកិច្ចគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍ដទៃទៀត កម្មវិធីមហាអនុតំបន់ទន្លេមេគង្គជួយកំណត់រក និង អនុវត្តគម្រោងអនុតំបន់ដែលមានអាទិភាពខ្ពស់ នៅក្នុងវិស័យជាច្រើន។

ដើម្បីសម្រេចបាននូវទស្សនវិស័យរបស់ខ្លួនសំដៅទទួលបានអនុតំបន់មួយដែលមានភាពរុងរឿង មានសមាហរណកម្ម និង មានភាពសុកដុមរមនា កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ បានអនុម័តប្រើប្រាស់យុទ្ធសាស្ត្រមួយដែលបែងចែកជាបីផ្នែក (យុទ្ធសាស្ត្រ C បីដង)៖

- បង្កើនការតភ្ជាប់ទំនាក់ទំនងតាមរយៈការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តប្រកបដោយនិរន្តរភាព និង ការផ្លាស់ប្តូររបៀងដឹកជញ្ជូនទៅជារបៀងសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន។
- កែលម្អភាពប្រកួតប្រជែងតាមរយៈការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពខ្ពស់ ចំពោះការធ្វើចលនាប្រជាជន និង ទំនិញឆ្លងកាត់ព្រំដែន និង សមាហរណកម្មទីផ្សារ ដំណើរការផលិតកម្ម និង ខ្សែសង្វាក់តម្លៃ ព្រមទាំង
- ការកសាងឱ្យមាននូវភាពជាម្ចាស់របស់សហគមន៍ តាមរយៈគម្រោង និងកម្មវិធីនានាដែលធ្វើការដោះស្រាយបញ្ហាកង្វល់ជារួមផ្នែកសង្គម និងបរិស្ថាន។

# ក្របខ័ណ្ឌយុទ្ធសាស្ត្រមហាអនុតំបន់ទន្លេមេគង្គ ២០១២-២០២២

មេដឹកនាំមហាអនុតំបន់ទន្លេមេគង្គ បានអនុម័តទៅលើក្របខ័ណ្ឌយុទ្ធសាស្ត្រមួយដែលមានរយៈពេល១០ ឆ្នាំ នៅឯកិច្ចប្រជុំកំពូលលើកទី៤របស់មហាអនុតំបន់ទន្លេមេគង្គ ក្នុងឆ្នាំ២០១១ ដើម្បីជាការណែនាំសម្រាប់មហាអនុតំបន់ទន្លេមេគង្គ ពីឆ្នាំ ២០១២ រហូតដល់ឆ្នាំ២០២២។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះពង្រឹងបន្ថែមទៅលើការប្តេជ្ញាចិត្តរបស់ប្រទេសជាសមាជិក និង ផែនការអភិវឌ្ឍន៍ជាតិ សំដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ នៅក្នុង និងក្រៅមហាអនុតំបន់ទន្លេមេគង្គ។

ប្រទេសជាសមាជិកមហាអនុតំបន់ទន្លេមេគង្គ បានបញ្ជាក់ជាថ្មីឡើងវិញអំពីទស្សនវិស័យ និងគោលដៅដែលផ្តល់ការចង្អុលទិសដល់កម្មវិធីនេះនាពេលបច្ចុប្បន្ន៖

- ប្រទេសមហាអនុតំបន់ទន្លេមេគង្គចង់មើលឃើញអនុតំបន់ទន្លេមេគង្គមួយដែលមានភាពរុងរឿង មានសមាហរណកម្ម និងមានភាពសុកសុមរមនាកាន់តែប្រសើរ។
- កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ នឹងរួមចំណែកសម្រេចឱ្យបាននូវសក្តានុពលរបស់អនុតំបន់ តាមរយៈ (១) បរិយាកាសគោលនយោបាយមួយដែលបង្កលក្ខណៈអំណោយផល និង ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយប្រសិទ្ធភាព ដែលនឹងសម្របសម្រួលដល់ការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ការវិនិយោគ ទេសចរណ៍ និងទម្រង់ដទៃទៀតនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង (២) ការអភិវឌ្ឍន៍ធនធានមនុស្ស និង សមត្ថភាពជំនាញ។
- ដើម្បីធានាថាដំណើរការអភិវឌ្ឍន៍នេះប្រកបដោយសមធម៌ និងមាននិរន្តរភាព គេត្រូវគោរពឱ្យបានពេញលេញ ចំពោះអត្ថប្រយោជន៍ផ្នែកបរិស្ថាន និងសង្គម ក្នុងការរៀបចំបង្កើត និងអនុវត្តកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ។

# ក្របខ័ណ្ឌវិនិយោគតំបន់

ក្របខ័ណ្ឌវិនិយោគតំបន់នៃមហាអនុតំបន់ទន្លេមេគង្គ (RIF) ដែលត្រូវបានអនុម័តដោយរដ្ឋមន្ត្រីមហា-អនុតំបន់ទន្លេមេគង្គ ក្នុងខែធ្នូ ឆ្នាំ២០១៣ បានរៀបចំឱ្យមានប្រតិបត្តិការក្របខ័ណ្ឌយុទ្ធសាស្ត្រ តាមរយៈការកំណត់រកដំណើរការនៃគម្រោងវិនិយោគ និងគម្រោងជំនួយបច្ចេកទេសអាទិភាព ពីឆ្នាំ២០១៣ រហូតដល់ឆ្នាំ២០២២។ ក្របខ័ណ្ឌវិនិយោគតំបន់ រួមមានជាង២០០គម្រោង នៅក្នុងវិស័យចំនួន១០ ដោយការប៉ាន់ប្រមាណទៅលើការវិនិយោគនេះ មានតម្លៃជាង ៥០ពាន់លានដុល្លា។

ផែនការអនុវត្តន៍ក្របខ័ណ្ឌវិនិយោគតំបន់ កំណត់រកឃើញដំណើរការដ៏ខ្លាំងក្លាមួយនៃគម្រោងដែលមានអាទិភាពខ្ពស់ចំនួន ៩២គម្រោង សម្រាប់ឆ្នាំ២០១៤-២០១៨ និងរៀបចំផែនការអនុវត្ត និងប្រព័ន្ធត្រួតពិនិត្យមួយដែលមានលក្ខណៈសមស្រប ក្នុងរយៈពេលមធ្យម។






# កម្មវិធីតាមវិស័យនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ

## ការដឹកជញ្ជូន

ការផ្តួចផ្តើមដឹកជញ្ជូនក្នុងមហាអនុតំបន់ទន្លេមេគង្គ មានគោលបំណងអភិវឌ្ឍន៍របៀងដឹកជញ្ជូនអាទិភាព ដែលភ្ជាប់អនុតំបន់ ជាមួយគ្នា និងផ្តល់តំណភ្ជាប់ការដឹកជញ្ជូនទៅកាន់តំបន់ទីប្រជុំជន តំបន់គោលដៅទេសចរណ៍ ទីផ្សារ និងមជ្ឈមណ្ឌលដទៃទៀតដែលមានសកម្មភាពសេដ្ឋកិច្ច។ សកម្មភាពនេះនឹងលើកកម្ពស់ការធ្វើពាណិជ្ជកម្ម ទេសចរណ៍ ការវិនិយោគ និង ការទទួលបានសេវាសង្គម និងសេវាដទៃទៀត។ របៀងដឹកជញ្ជូនសំខាន់ៗ បង្កើតបានជាមូលដ្ឋាននៃរបៀងសេដ្ឋកិច្ចចម្បងៗចំនួន៣ នៃមហាអនុតំបន់ទន្លេមេគង្គ ដែលរួមមានជាអាទិ៍៖ (១) របៀងសេដ្ឋកិច្ចភាគខាងជើង-ត្បូង (២) របៀងសេដ្ឋកិច្ចភាគខាងកើត-លិច និង (៣) របៀងសេដ្ឋកិច្ចភាគខាងត្បូង (សូមមើលផែនទី)។

## ការដឹកជញ្ជូន និងការសម្របសម្រួលពាណិជ្ជកម្ម



ការដឹកជញ្ជូន និងការសម្របសម្រួលពាណិជ្ជកម្មនៅក្នុងមហាអនុ-តំបន់ទន្លេមេគង្គ ផ្តោតលើផ្នែកអរូបវ័ន្ត ឬ "ធាតុទន់ - software" ដែលអាចលើកកម្ពស់ទំនាក់ទំនង និង ការតភ្ជាប់ទំនាក់ទំនងរវាងបណ្តាប្រទេសជាសមាជិក ដើម្បីបង្កើនការធ្វើពាណិជ្ជកម្ម និងការវិនិយោគឆ្លងកាត់ព្រំដែន។ កិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែនក្នុងមហាអនុតំបន់ទន្លេមេគង្គផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់កិច្ចខិតខំសម្របសម្រួលដល់ការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្ម ដើម្បីសម្របសម្រួលដល់ការធ្វើចលនាទំនិញ យានយន្ត និងមនុស្ស នៅក្នុងអនុតំបន់ឆ្លងកាត់ព្រំដែនប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ថាមពល



កិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គនៅក្នុងវិស័យថាមពលមានគោលបំណងបង្កើតឱ្យមាននូវទីផ្សារថាមពលតំបន់មួយដែលមានការប្រកួតប្រជែង និងប្រកបដោយសមាហរណកម្ម ដែលនឹងធ្វើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនូវធនធានថាមពលដ៏សម្បូរបែបរបស់មហាអនុតំបន់ទន្លេមេគង្គ សំដៅកែលម្អសន្តិសុខផ្នែកថាមពលរបស់អនុតំបន់ និងលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានការផ្គត់ផ្គង់ថាមពលដែលមានលក្ខណៈទំនើប និងអាចមានលទ្ធភាពប្រើប្រាស់បាន។

## កសិកម្ម

កម្មវិធីគាំទ្រវិស័យកសិកម្មស្នូលនៃមហាអនុតំបន់ទន្លេមេគង្គ ដំណាក់កាលទី២ (២០១១-២០២០) ចង់មើលឃើញអនុតំបន់មួយដែលមានការទទួលស្គាល់ជាសកលថាជាអ្នកផលិតស្បៀងអាហារប្រកបដោយសុវត្ថិភាពឈានមុខគេ ដោយប្រើប្រាស់ការអនុវត្តន៍កសិកម្មដែលមិនប៉ះពាល់ដល់អាកាសធាតុ និង ការធ្វើសមាហរណកម្មទៅក្នុងទីផ្សារសកលតាមរយៈរបៀងសេដ្ឋកិច្ចតំបន់។

## បរិស្ថាន

កម្មវិធីបរិស្ថានស្នូលនៃមហាអនុតំបន់ទន្លេមេគង្គ មានគោលបំណងបង្កើតតំបន់មួយដែលសម្រេចបានកំណើនសេដ្ឋកិច្ច និង កិច្ចការពារបរិស្ថាន ស្របពេលជាមួយគ្នា។ កម្មវិធីបរិស្ថានស្នូលដំណាក់កាលទី២

(២០១២-២០១៦) ផ្តោតលើប្រធានបទអាទិភាពចំនួន៣៖ ការអភិរក្សជីវចម្រុះ និង ការកាត់បន្ថយភាពក្រីក្រ ការបន្សាំ និង ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និង ការអភិវឌ្ឍន៍សមត្ថភាព។

## ការអភិវឌ្ឍន៍ធនធានមនុស្ស

យុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍន៍ធនធានមនុស្សនៃមហាអនុតំបន់ទន្លេមេគង្គ ផ្តោតលើការលើកកម្ពស់កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យសុខាភិបាល អប់រំ ការងារ និងទេសន្តរប្រវេសន៍ និង ការអភិវឌ្ឍន៍សង្គម។ ការផ្តួចផ្តើមសហប្រតិបត្តិការ ក៏រាប់បញ្ចូលកម្មវិធីត្រួតពិនិត្យជំងឺឆ្លង និង ការបង្ការមេរោគអេដស៍/ជំងឺអេដស៍ ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ការបណ្តុះបណ្តាលបច្ចេកទេស និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងការអប់រំកម្រិតឧត្តមសិក្សា និង ការស្រាវជ្រាវ។

## ការអភិវឌ្ឍន៍តំបន់ទីក្រុង

ការអភិវឌ្ឍន៍តំបន់ទីក្រុងនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ផ្តោតលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាអាទិភាពនៅតំបន់ទីក្រុង តាមតំបន់ទីប្រជុំជនខ្នាតតូច និងមធ្យម ដែលស្ថិតនៅតាមបណ្តោយរបៀងដឹកជញ្ជូនមហាអនុតំបន់ទន្លេមេគង្គ។ បន្ថែមពីលើការដោះស្រាយបញ្ហាកំណើនប្រជាជន ការវិនិយោគទាំងនេះនឹងរួមចំណែកដល់ការផ្លាស់ប្តូររបៀងដឹកជញ្ជូនទៅជារបៀងសេដ្ឋកិច្ច និង ផ្តល់ឱ្យតំបន់ជនបទនូវលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានការងារ និងទីផ្សារ។



## ទេសចរណ៍

វិស័យទេសចរណ៍នៃមហាអនុតំបន់ទន្លេមេគង្គ អភិវឌ្ឍ និងលើកកម្ពស់មហាអនុតំបន់ទន្លេមេគង្គ ជាតំបន់គោលដៅតែមួយ ដោយផ្តល់នូវពិពិធភាពផលិតផលអនុតំបន់ដែលមានគុណភាពល្អ និងមានទិន្នផលខ្ពស់ ដែលជួយបែងចែកប្រយោជន៍ដែលទទួលបានពីវិស័យទេសចរណ៍ឱ្យបានកាន់តែទូលំទូលាយ ខណៈពេលកាត់បន្ថយផលប៉ះពាល់អវិជ្ជមានឱ្យបានជាអតិបរមា។ ការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់វិស័យទេសចរណ៍ រួមផ្សំជាមួយនឹងការកសាងសមត្ថភាព និងការបណ្តុះបណ្តាល ព្រមទាំងការអភិវឌ្ឍន៍វិស័យទេសចរណ៍ផ្អែកលើសហគមន៍ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ការបង្កើតការងារ និងការអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាព។

## បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

កិច្ចខិតខំផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ មានគោលបំណងធ្វើឱ្យមានភាពប្រសើរឡើងចំពោះការតភ្ជាប់ទំនាក់ទំនងទូរគមនាគមន៍ លើកកម្ពស់ការអនុវត្តន៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងសម្របសម្រួលដល់ការបង្កើនលទ្ធភាពទទួលបានព័ត៌មាន និងគមនាគមន៍ក្នុងតម្លៃប្រតិបត្តិការកាន់តែទាប និង ជម្រុញឱ្យមានការប្រកួតប្រជែងនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។

## ពហុវិស័យដទៃទៀត និងតំបន់សេដ្ឋកិច្ចនៅតាមព្រំដែន

ការផ្តោតយកចិត្តទុកដាក់នៃក្របខ័ណ្ឌយុទ្ធសាស្ត្រមហាអនុតំបន់ទន្លេមេគង្គ ទៅលើការអភិវឌ្ឍន៍របៀងសេដ្ឋកិច្ច បានជម្រុញឱ្យមានការកើនឡើងចំពោះចំណាប់អារម្មណ៍ទៅលើតំបន់សេដ្ឋកិច្ចពិសេស ជាពិសេសគឺតំបន់សេដ្ឋកិច្ចនៅតាមព្រំដែន ដែលទាមទារឱ្យមានការសម្របសម្រួលរវាងពហុវិស័យ។ ការបង្កើនប្រយោជន៍នៃរបៀងសេដ្ឋកិច្ចឱ្យបានជាអតិបរមា នឹងទាមទារឱ្យមានគម្រោងពហុវិស័យកាន់តែច្រើន ដែលពាក់ព័ន្ធទៅនឹងការវិនិយោគវិស័យសាធារណៈ និងវិស័យឯកជន ដោយគម្រោងទាំងនោះរាប់បញ្ចូលទាំងអន្តរាគមន៍ធាតុរឹង (hardware) និងធាតុទន់ (software)។

## ការអភិវឌ្ឍន៍របៀងសេដ្ឋកិច្ចនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ

យុទ្ធសាស្រ្តវិស័យដឹកជញ្ជូនមហាអនុតំបន់ទន្លេមេគង្គ (២០០៦-២០១៥) កំណត់រកឃើញរបៀងផ្លូវថ្នល់ចំនួន៩ ដែលនឹងបង្កើតបាននូវបណ្តាញទំនាក់ទំនងដឹកជញ្ជូនក្នុងអនុតំបន់។ របៀងផ្លូវថ្នល់ទាំងនោះបង្កើតបាននូវមូលដ្ឋាននៃការអភិវឌ្ឍន៍ “របៀងសេដ្ឋកិច្ច” ដែលធ្វើសមាហរណកម្មការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាមួយការធ្វើពាណិជ្ជកម្ម ការវិនិយោគ និង កាលានុវត្តភាពសេដ្ឋកិច្ចដទៃទៀត នៅក្នុងតំបន់ភូមិសាស្រ្តមួយចំនួនដែលត្រូវបានកំណត់ គួបផ្សំជាមួយនឹងការបំពេញបន្ថែមពីកិច្ចខិតខំដោះស្រាយផលប៉ះពាល់ផ្នែកសង្គម បរិស្ថាន និងផលប៉ះពាល់ដទៃទៀត ដែលបណ្តាលមកពីការកើនឡើងនៃការតភ្ជាប់ទំនាក់ទំនង។





## កម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចនៃមហាអនុតំបន់ទន្លេមេគង្គ

មហាអនុតំបន់ទន្លេមេគង្គ (GMS) រួមមានប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន (PRC ជាពិសេសគឺ ខេត្តយូនណាន និងតំបន់ស្វយ័ត គ័ងស៊ី ហ្សួង) សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (Lao PDR) មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

ក្នុងឆ្នាំ១៩៩២ ដោយមានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង តាមរយៈការពង្រឹងបន្ថែមទៅលើប្រវត្តិសាស្ត្រ និងវប្បធម៌របស់ពួកគេដែលមានលក្ខណៈស្រដៀងគ្នា ប្រទេសទាំង៦នៃមហាអនុតំបន់ទន្លេមេគង្គបានធ្វើការផ្សព្វផ្សាយកម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចអនុតំបន់ (កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ) ដើម្បីលើកកម្ពស់ទំនាក់ទំនងសេដ្ឋកិច្ចរបស់ពួកគេ ដែលគ្របដណ្តប់ជាបឋមទៅលើវិស័យអាទិភាពចំនួន៩ ៖ កសិកម្ម, ថាមពល, បរិស្ថាន, ការអភិវឌ្ឍន៍ធនធានមនុស្ស, ការវិនិយោគ, ទូរគមនាគមន៍, ទេសចរណ៍, ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និង ការដឹកជញ្ជូននិងការសម្របសម្រួលពាណិជ្ជកម្ម។ ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍ ដទៃទៀត កម្មវិធីមហាអនុតំបន់ទន្លេមេគង្គកំពុងជួយដល់ប្រទេសដែលចូលរួមនៅក្នុងកម្មវិធីនេះ សម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ តាមរយៈការបង្កើនការតភ្ជាប់ទំនាក់ទំនង ការកែលម្អប្រសិទ្ធភាព និង ភាពជាម្ចាស់របស់សហគមន៍ឱ្យបានកាន់តែប្រសើរជាងនេះ (យុទ្ធសាស្ត្រ C បីដង)។

## អំពីធនាគារអភិវឌ្ឍន៍អាស៊ី

ទស្សនវិស័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺតំបន់អាស៊ី និងប៉ាស៊ីហ្វិកគ្មានភាពក្រីក្រ។ ធនាគារអភិវឌ្ឍន៍អាស៊ីមានបេសកកម្មជួយដល់សមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការកាត់បន្ថយភាពក្រីក្រ និងកែលម្អគុណភាពជីវិតរស់នៅរបស់ប្រជាពលរដ្ឋពួកគេ។ បើទោះបីជាមានជោគជ័យជាច្រើននៅក្នុងតំបន់រួចមកហើយក៏ដោយ ក៏តំបន់នេះនៅតែបន្តជាតំបន់ដែលមានប្រជាពលរដ្ឋក្រីក្រភាគច្រើនក្នុងពិភពលោក។ ធនាគារអភិវឌ្ឍន៍អាស៊ី ប្តេជ្ញាកាត់បន្ថយភាពក្រីក្រតាមរយៈកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា កំណើនដែលធានាបាននូវនិរន្តរភាពបរិស្ថាន និងសមាហរណកម្មតំបន់។

ដោយមានមូលដ្ឋាននៅក្នុងទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ីមានសមាជិកចំនួន៦៧ប្រទេស ក្នុងនោះរួមមាន ៤៨ប្រទេសនៅក្នុងតំបន់នេះ។ វិធីសាស្ត្រចម្បងៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការជួយដល់សមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍របស់ខ្លួន រួមមានជាអាទិ៍ កិច្ចសន្ទនានៅកម្រិតគោលនយោបាយ កម្ចី ការវិនិយោគភាគហ៊ុន ការធានាហិរញ្ញវត្ថុ ការផ្តល់ជំនួយឥតសំណង និងជំនួយបច្ចេកទេស។

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លេខាធិការដ្ឋាន GMS
នាយកដ្ឋានអាស៊ីអាគ្នេយ៍ ធនាគារអភិវឌ្ឍន៍អាស៊ី
gms@adb.org • www.adb.org/gms

រូបភាពទាំងអស់គឺជារូបភាពរបស់ ADB។

Creative Commons Attribution 3.0 IGO license (CC BY 3.0 IGO)

© 2015 ADB. អាជ្ញាប័ណ្ណ CC មិនអាចយកមកអនុវត្តបានចំពោះឯកសារដែលគ្មានការរក្សាសិទ្ធិ ដែលមិនមានជាឯកសាររបស់ ADB នៅក្នុងឯកសារនេះបានឡើយ។ លេខស្តុកបោះពុម្ព ARM157280-2។

បោះពុម្ពនៅលើក្រដាសកែច្នៃឡើងវិញ